ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

# សារលិខិតរំលែកទុក្ខ

**ជូនចំពោះ**
**លោកជំទាវ អ៊ុក គឹមអុន និងក្រុមគ្រួសារ**

ក្នុងនាមក្រុមប្រឹក្សាធម្មនុញ្ញ ខ្ញុំនិងភរិយា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានសេចក្តីក្រៀមក្រំក្រៃលែង និងសោកស្តាយជាអនេក ចំពោះដំណឹងអំពីមរណភាពរបស់ឯកឧត្តម **ពិត តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង ២:៤៥ នាទី ក្នុងជន្មាយុ ៧៥ឆ្នាំ ដោយរោគាពាធ។

យើងខ្ញុំ សូមចូលរួមរំលែកមរណទុក្ខជាមួយនឹងលោកជំទាវ **អ៊ុក គឹមអុន** និងក្រុមគ្រួសារ ចំពោះការបាត់បង់ឧត្តមស្វាមី ឪពុក ឪពុកក្មេក និងជីតា ជាទីគោរពស្រឡាញ់ និងប្រកបដោយព្រហ្មវិហារធម៌ ហើយក៏ជាការបាត់បង់នូវបញ្ញវន្តដ៏ឆ្នើមនិងជាឥស្សរជនខ្មែរមួយរូប ដែលបានលះបង់កម្លាំងកាយ ប្រាជ្ញាស្មារតី ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជាពលរដ្ឋ ព្រមទាំងបានចូលរួមចំណែកយ៉ាងសកម្មក្នុងស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញតាំងពីឆ្នាំ១៩៩៨ ក្នុងដំណើរការជានាការពារនូវការគោរពរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ និងជាពិសេសឯកឧត្តមបានចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយវិវាទនៃការបោះឆ្នោតជាច្រើនអាណត្តិកន្លងមក ដែលជាការរួមចំណែកក្នុងការលើកកម្ពស់នីតិរដ្ឋនិងលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

យើងខ្ញុំ សូមលំឱនកាយលើកហត្ថបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមជួយបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធឯកឧត្តម **ពិត តាំងសាន** បានទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកជំទាវនិងក្រុមគ្រួសារ មេត្តាទទួលនូវការចូលរួមរំលែកមរណទុក្ខដ៏សែនក្រៀមក្រំបំផុតនេះ ដោយស្មោះអស់ពីដួងចិត្តនៃយើងខ្ញុំទាំងអស់គ្នា។ ៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**អ៊ឹម ឈុនលឹម**